# មេរៀនទី ៤៧: យ៉ូសែបបានអត់ទោសឱ្យបងប្អូនរបស់គាត់

## លោកុប្បត្តិ ៤២-៤៥

**គោលបំណង៖** ព្រះចង់ឲ្យយើងចេះអត់ទោស។

**ខគម្ពីរចងចាំ៖** ម៉ាថាយ ៦:១២ *"សូមអត់ទោសសេចក្តីកំហុសរបស់យើងខ្ញុំ ដូចជាយើងខ្ញុំបានអត់ទោសដល់អស់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ក្នុងនាមជាគ្រីស្ទបរិស័ទ យើងមានអំណរដែលយើងទទួលបាននូវការការពារ និងសេចក្តីសន្យារបស់ព្រះដែលប្រកបដោយសេចក្តីស្រឡាញ់ចំពោះយើង។ ដូច្នេះវាជាការចាំបាច់ និងជាធម្មជាតិដែលយើងត្រូវអត់ទោសដល់អ្នកដែលធ្វើឱ្យយើងខកចិត្ត ឬធ្វើឱ្យយើងឈឺចាប់។ ក្នុងនាមជាអ្នកបម្រើនៃនគររបស់ព្រះ វាសំខាន់ណាស់ដែលយើងត្រូវចេះអត់ទោសដល់អ្នកដែលធ្វើខុសចំពោះយើង។ តើអ្នកកំពុងរងទុក្ខដោយសារតែនរណាម្នាក់ធ្វើឱ្យអ្នកឈឺចាប់ ឬក៏អ្នកពិបាកនឹងអត់ឱនទោសឱ្យនរណាម្នាក់ឬ? សូមពិចារណាអំពីការលំបាកដែលយ៉ូសែបបានឆ្លងកាត់។ សូមអានរឿងរបស់គាត់ឡើងវិញ ហើយទូលសូមឱ្យព្រះប្រទានកម្លាំង និងប្រាជ្ញាដល់អ្នកដូចអ្វីដែលព្រះបានផ្តល់ឱ្យយ៉ូសែបដើម្បីអភ័យទោសដល់បងប្អូនរបស់គាត់ដែរ។

**ចំរៀង៖** ១. គ្រប់ទាំងអស់ខ្ញុំអាចធ្វើបាន ២.ខ្ញុំអាចធ្វើគ្រប់ការ ៣. ខ្ញុំដឹងខ្លួនហើយ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «ព្រះបានអត់ទោសឲ្យយើងនៅពេលដែល...»

**"ព្រះបានអត់ទោសឲ្យយើងនៅពេលដែល..."**



១. សូមឲ្យកុមារទាំងអស់ក្រោកឈរឡើង។

២. ពួកគេអាចអង្គុយចុះនៅពេលដែលគេឆ្លើយនិងសំណួររួច៖

« ព្រះបានអត់ទោសឲ្យយើងរាល់គ្នានៅពេលដែល...» (ចម្លើយអាចជាៈ និយាយកុហក ឈ្លោះប្រកែកគ្នា មិនស្តាប់បង្គាប់ឪពុកម្តាយឬនិយាយពាក្យអាក្រក់ជាដើម)

៣. ប្រសិនបើអ្នកត្រូវការសំនួរផ្សេងទៀត អ្នកអាចសួរកុមារថា "ខ្ញុំបានអត់ទោសឲ្យអ្នកដទៃនៅពេលពួកគេ..." ។

### ៤. ការណែនាំមេរៀន

រឿងដ៏អស្ចារ្យមួយអំពីព្រះគឺទ្រង់អាចនាំមកនូវការល្អគ្រប់យ៉ាង, មិនថាវាជារឿងអាក្រក់ប៉ុណ្ណាក៏ដោយ។ ព្រះគម្ពីរបានបង្រៀនយើងជាច្រើនអំពីអ្វីដែលព្រះជាម្ចាស់បានធ្វើ និងថាតើព្រះទ្រង់ជានរណា។ ព្រះគម្ពីរក៏បង្រៀនយើងផងដែរថា យើងគួរតែធ្វើឲ្យដូចជាអ្នកណា? ព្រះទ្រង់ជាអ្នកអត់ទោសចំពោះបាបរបស់យើងរាល់គ្នា។ ដោយព្រោះបានអត់ទោសដល់យើង យើងក៏ត្រូវតែចេះអត់ទោសដល់អ្នកដទៃផងដែរ។ តើកូនៗឃើញថាការនេះទាក់ទងគ្នា

យ៉ាងណាដែរឬទេ? នៅពេលដែលនរណាម្នាក់វាយកូន, វាជារឿងធម្មតាទេដែលយើងចង់វាយគេវិញ។ រឺក៏នៅពេលដែលនរណាម្នាក់និយាយអាក្រក់ដាក់យើង យើងក៏និយាយពាក្យអាក្រក់ទៅគេវិញដែរ។ ប៉ុន្តែព្រះគម្ពីរនៅថ្ងៃនេះបានបង្រៀនយើងថា យើងត្រូវតែចេះអត់ទោសឱ្យគ្នា។ យើងអាចអត់ឱនទោសបានគឺដោយសារតែយើងស្គាល់ព្រះ ហើយទ្រង់បានអត់ទោសឱ្យយើង។ នៅពេលយើងចេះអភ័យទោសដូចជាព្រះអង្គបានធ្វើ នោះយើងកំពុងតែធ្វើឲ្យព្រះអង្គដឹងថាយើងអរព្រះគុណចំពោះការអត់ទោសរបស់ទ្រង់ហើយយើងទុកចិត្តទ្រង់។ តាមពិតការអត់ទោសគឺជាវិធីមួយដែលព្រះនាំមកនូវការល្អដែលកើតចេញពីការអាក្រក់។ សូមមើលពីរបៀបដែលយ៉ូសែបអាចនាំយកការល្អចេញពីស្ថានភាពដ៏អាក្រក់បាន!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

យ៉ូសែបមានបងប្រុស១០នាក់និងប្អូនប្រុសម្នាក់។ បងប្រុសទាំង១០របស់យ៉ូសែបបានច្រណែនហើយស្អប់គាត់នៅពេលពួកគេមានឱកាសពួកគេបានលក់គាត់ធ្វើជាទាសករ។ យ៉ូសែបត្រូវបានបញ្ជូនឲ្យធ្វើជាទាសករនៅអេស៊ីព្ទហើយគាត់ក្លាយជាទាសករនៅទីនោះអស់រយៈពេល១៣ឆ្នាំ។ បន្ទាប់មកស្តេចបានសុំឲ្យគាត់កាត់ស្រាយសុបិន្តមួយឱ្យទ្រង់។ ដោយមានជំនួយមកពីព្រះ យ៉ូសែបបានធ្វើការយ៉ាងល្អក្នុងការបកស្រាយសុបិន្តនោះ ។ គាត់បានប្រាប់ស្តេចថានឹងមាន៧ឆ្នាំនៃភាពបរិបូរណ៍ និង៧ឆ្នាំនៃភាពអត់ឃ្លាន។ ស្តេចបានផ្តល់ឲ្យយ៉ូសែបនូវឋានៈខ្ពស់បំផុតលំដាប់ទីពីរនៅក្នុងប្រទេសអេស៊ីព្ទ ហើយបានប្រាប់យ៉ូសែបឲ្យជួយប្រជាជនអេស៊ីព្ទក្នុងការសន្សំសំចៃស្បៀងអាហារដើម្បីកុំឲ្យពួកគេត្រូវអត់ឃ្លានក្នុងពេលទុរ្ភិក្ស(គ្រោះធម្មជាតិ)មកដល់ ព្រោះដំណាំរបស់ពួកគេមិនទទួលបានទិន្នផលទេ។

បងប្អូនរបស់យ៉ូសែបរស់នៅស្រុកកាណានដែលនៅក្បែរស្រុកអេស៊ីព្ទ ហើយពួកគេមានការស្រេកឃ្លានព្រោះគ្មានម្ហូបអាហារទេនៅស្រុកកាណាន។ ដូច្នេះពួកគេបានធ្វើដំណើរទៅប្រទេសអេស៊ីព្ទដើម្បីទិញស្បៀងអាហារ។ ពួកគេត្រូវទិញអាហារពីយ៉ូសែបតែពួកគេមិនស្គាល់គាត់ទេ។ យ៉ូសែបបានក្លាយជាបុរសដ៏មានអំណាចម្នាក់នៅក្នុងប្រទេសអេស៊ីព្ទ។ ទោះបីជាមានរឿងអ្វីក៏យ៉ូសែបនៅតែស្គាល់បងប្អូនរបស់គាត់ដែរ។ គាត់បានធ្វើការសាកល្បងជាច្រើនដងចំពោះបងៗរបស់គាត់ ដើម្បីដឹងថាតើពួកគេនៅតែអាក្រក់ ឬយ៉ាងណា។ នៅពេលដែលយ៉ូសែបបានឃើញថាបងប្អូនរបស់គាត់បានផ្លាស់ប្រែហើយ គាត់បាននិយាយ ថា “ខ្ញុំជាយ៉ូសែបប្អូនប្រុសរបស់បងៗ។ ខ្ញុំគឺជាអ្នកដែលបងៗបានលក់ជាទាសករ។ បងៗចង់ធ្វើបាបខ្ញុំ ប៉ុន្តែព្រះបានបង្កើតរឿងល្អចេញពីរឿងនេះ! ខ្ញុំអត់ទោសឱ្យបងៗបាន”។ យ៉ូសែបបានអញ្ជើញបងៗនិងឪពុករបស់គាត់ឲ្យប្តូរទៅរស់នៅឯអេស៊ីព្ទ ដែលជាកន្លែងមានអាហារច្រើន។ យ៉ូសែបបានចិញ្ចឹមថែរក្សាពួកគេគ្រប់គ្នា។

យ៉ូសែបអាចចាប់បងៗរបស់គាត់ដាក់គុកបានពីបទលក់គាត់ជាទាសករឬដោយសារពួកគេធ្វើអាក្រក់ដាក់គាត់។ ប៉ុន្តែយ៉ូសែបបានអត់ទោសឱ្យពួកគេវិញ នេះគឺដោយសារគាត់ស្រឡាញ់និងទុកចិត្តព្រះ។

## ៦. សំនួរពិភាក្សា

១.ហេតុអ្វីបានជាបងប្អូនរបស់យ៉ូសែបស្អប់គាត់? *ដោយសារពួកគាត់ច្រណែន*

២.តើយ៉ូសែបបានធ្វើជាទាសករនៅឯប្រទេសណា? *អេស៊ីព្ទ*

៣.ហេតុអ្វីបងប្អូនរបស់យ៉ូសែបធ្វើដំណើរទៅប្រទេសអេស៊ីព្ទ? *ដើម្បីទិញស្បៀងអាហារ*

៤.ហេតុអ្វីបានជាយ៉ូសែបអភ័យទោសឲ្យបងប្អូនរបស់គាត់?

*ព្រោះគាត់ស្រឡាញ់ និងទុកចិត្តព្រះ ព្រោះវាជាបញ្ជារបស់ព្រះ*

៥.បើមានគេធ្វើបាបប្អូនៗតើប្អូនឆ្លើយតបទៅគេវិញយ៉ាងដូចម្ដេច? *ឱ្យកុមារឆ្លើយ*

## ៧. ល្បែងកំសាន្ត «រង្វង់នៃការអភ័យទោស»




១. គូសរង្វង់ធំមួយនៅលើដី

២. យើងទាំងអស់គ្នាបានធ្វើការអាក្រក់មួយ ហើយយើងមានការសោកស្ដាយចំពោះការដែលយើងបានធ្វើនោះ។ នៅពេលយើងធ្វើការអាក្រក់ យើងឈរនៅក្រៅរង្វង់នៃការអភ័យទោស។ ប៉ុន្តែព្រះបានមានបន្ទូលថា ប្រសិនបើយើងប្រាប់ទ្រង់ពីអ្វីដែលយើងបានធ្វើ នោះទ្រង់នឹងអត់ទោសឱ្យយើង។ ហើយព្រះក៏ប្រាប់យើងថាយើងអាច អត់ទោសឱ្យគ្នាទៅវិញទៅមកបាន។

៣. គ្រូឈរនៅកណ្ដាលរង្វង់ នៅពេលកុមារឮចម្រៀងសូមឈរនៅឱ្យស្ងៀម។ នៅពេលភ្លេងឈប់កុមារឈានពីរជំហានប៉ុណ្ណោះឆ្ពោះទៅរករង្វង់នៃការអភ័យទោស។

៤. នៅពេលពួកគេដើរចូលកៀកក្បែររង្វង់ដែលគ្រូអាចប៉ះដៃកុមារបាន ហើយគ្រូនិយាយថា “ អ្នកត្រូវបានអត់ទោសឱ្យហើយ” កុមារអាចចូលទៅក្នុងរង្វង់ជាមួយគ្រូបាន។

៥. បន្ទាប់មកឲ្យកុមារដែលនៅក្នុងរង្វង់អាចប៉ះដៃកុមារផ្សេងទៀតដែលនៅខាងក្រៅរង្វង់ ដោយនិយាយថា “អ្នកត្រូវបានអត់ទោសឲ្យហើយ” ដល់អ្នកផ្សេងផងដែរ។ ធ្វើបែបនេះរហូតដល់សិស្សគ្រប់គ្នាបានចូលមកនៅក្នុងរង្វង់បា។

## ៨. ខគម្ពីរចងចាំ ម៉ាថាយ ៦:១២

## ៩. ហត្ថកម្ម

**សម្ភារៈដែលត្រូវការ៖** ក្រដាសកាតុង ក្រដាស A4(ពណ៌ទឹកក្រូច និងពណ៌ស) កន្ត្រៃ និងកាវបិត

១. សូមបោះពុម្ពក្រដាសហត្ថកម្មនៅទំព័រខាងក្រោម និងចែកឱ្យកុមារម្នាក់ ១ សន្លឹក

២. ឲ្យកុមារគូសផ្ដាមបាតដៃរបស់ពួកគេនៅលើក្រដាសកាតុង ហើយកាត់វាចេញមក (រូបដៃសងខាង)

២. កាត់រូបមនុស្សពាក់កណ្ដាលខ្លួន (ក្នុងក្រដាសហត្ថកម្ម) ហើយឲ្យកុមារតុបតែងនិងគូររូបមនុស្សនៅលើក្រដាសនោះ ដោយសរសេរខគម្ពីរចងចាំនៅចំកណ្ដាល

៣. កាត់ក្រដាសជារាងចតុកោណកែងវែងមួយ (ប្រើក្រដាសពណ៌ទឹកក្រូច) ហើយយករូបបាតដៃដែលបានកាត់រួចនោះមកបិតភ្ជាប់ជាមួយគ្នានៅចុងសងខាង។

៤. បិតរូបពាក់កណ្ដាលខ្លួននៅចំកណ្ដាលក្រដាសចតុកោណនោះ




**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*



